**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារ៉ូ យូជី**
**ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីប្រគល់ទទួលឧបករណ៍ផ្តល់ដោយជំនួយឥតសំណងក្រៅគម្រោងរបស់ជប៉ុនឆ្នាំ ២០១១**
**ដើម្បីរួមចំណែកដល់ការស្តារ និង កិច្ចប្រឹងប្រែងការពារគ្រោះមហន្តរាយសំរាប់ ប្រជាជននិង**
**តំបន់ដែលរងផលប៉ះពាល់ដោយសារគ្រោះមហន្តរាយទឹកជំនន់ ក្នុងឆ្នាំ ២០១១**
**ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៣**

- សូមគោរព ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន
- សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និង អស់លោកទាំងអស់

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានមកចូលរួមពិធីប្រគល់ទទួលឧបករណ៍ផ្តល់ដោយជំនួយឥតសំណងក្រៅគម្រោងរបស់ជប៉ុនឆ្នាំ ២០១១ ដើម្បីរួមចំណែកដល់ការស្តារ និង កិច្ចប្រឹងប្រែងការពារគ្រោះមហន្តរាយសំរាប់ប្រជាជន និង តំបន់ដែលរងគ្រោះដោយសារគ្រោះទឹកជំនន់ ក្នុងឆ្នាំ ២០១១។ ជាបឋម ខ្ញុំសូមសម្តែងនូវការដឹងគុណដោយស្មោះសរចំពោះ ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូនដែលបានរៀបចំឱ្យមានពិធីនេះឡើង ។

ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរ ដែលពិធីសម្រាប់គម្រោងដ៏សំខាន់នេះត្រូវបានប្រារព្ធឡើងនៅក្នុងបរិបទដ៏ពិសេសនៃឆ្នាំ ២០១៣ នេះ ដែលជាឆ្នាំខួបអនុស្សាវរីយ៍លើកទី ៦០ នៃទំនាក់ទំនងជាមិត្តភាពជប៉ុន-កម្ពុជា ។

នៅឆ្នាំ ២០១១ ភ្លៀងបានធ្លាក់យ៉ាងខ្លាំង ហើយបន្ទាប់ពីនោះជំនន់ទឹកភ្លៀងបានបង្កអោយមានការខូចខាតនៅតំបន់ជាច្រើននៃប្រទេសកម្ពុជា។ បណ្តាញផ្លូវថ្នល់ដែលជាហេដ្ឋារចនាសម្ព័ន្ធដ៏សំខាន់សម្រាប់ប្រជាជននៅមូលដ្ឋានបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារភក់ជ្រាំដែលរំខានដល់សកម្មភាពសេដ្ឋកិច្ច និង សង្គមនៅតំបន់ខ្លះ។

ប្រទេសជប៉ុនមានការយល់ដឹងច្បាស់ណាស់អំពីស្ថានភាពនៅប្រទេសកម្ពុជា និង បានដាក់អាទិភាពខ្ពស់នៅក្នុងការផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួនចំពោះកម្ពុជានៅក្នុងវិស័យការពារគ្រោះទឹកជំនន់។ នៅខែ តុលា ឆ្នាំ ២០១១ រដ្ឋាភិបាលជប៉ុនបានឆ្លើយតបជាបន្ទាន់ចំពោះមុខការខូចខាតដោយគ្រោះទឹកជំនន់តាមរយៈការបញ្ជូនជំនួយសង្គ្រោះបន្ទាន់ ហើយបន្ទាប់ពីនោះមកបានសំរេចចិត្តដើម្បីដំណើរការគម្រោងស្តារ និង ជួសជុលឡើងវិញនេះ។ គម្រោងនេះមានទឹកប្រាក់

សរុបចំនួន ៦០០ លានយ៉េនប្រាក់ជប៉ុន ( ប្រហាក់ប្រហែលស្មើនឹង ៦ លានដុល្លារអាមេរិក) ដែលមានគោលបំណង ស្តារ និង ការពារគ្រោះមហន្តរាយតាមរយៈការផ្តល់គ្រឿងចក្រសម្រាប់ការសាងសង់ បរិក្ខារផ្សេងៗ រួមទាំងគ្រឿងបន្លាស់។ ការបណ្តុះបណ្តាលសម្រាប់ប្រតិបត្តិការ និង ការថែទាំគ្រឿងចក្រ ក៏ត្រូវបានផ្តល់ជូនផងដែរជាផ្នែកទន់នៃគម្រោងនេះ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគំរោងនេះនឹងជួយពន្លឿនសកម្មភាពស្តារឡើងវិញនូវការខូចខាតដោយទឹកជំនន់ និង ជួយធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជននៅមូលដ្ឋានក៏ដូចជាជួយធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពនៃការជួសជុលថែទាំផ្លូវថ្នល់។

ចុងបញ្ចប់នេះ ខ្ញុំសង្ឃឹមដោយស្មោះសរថាកិច្ចសហប្រតិបត្តិការពីសំណាក់រដ្ឋាភិបាល និងប្រជាជនជប៉ុន នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានជាយូរអង្វែងមកហើយនេះរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា ។

សូមអរគុណ ។